**៣.-សម្រេកជីវិត - សម្រិតគម្លាន**

- ស្រឡាញ់ខ្លួន ឱ្យ ស្ងួនចំណី
- ស្រឡាញ់ទឹកដី ឱ្យ ប្រណីទឹកចិត្ត
- ស្រឡាញ់ជីវិត ឱ្យ ប្រព្រឹត្តទានសីល សមាធិ និងបញ្ញា ដោយប្រណម្យ យ៉ាងប្រណីត ដ៏ស្និតស្នាញ ។

**ចៅកកែ**

ចាប់ តាំងពីឆ្នាំ ១៩៤២ ដល់១៩៤៩ កុមារ គិមស្នួគិ បានរស់ នៅ ក្នុងភូមិ អូរស្រឡៅ ខាងកើត ជាមួយឪពុក ម្ដាយ ចិញ្ចឹម អុំ មីងមា បងប្អូនជីដូនមួយ ធម្មជាតិ និងសត្វជាតុ តាមធម្មតា ។

ឆ្នាំ ១៩៤៦ ឪពុក ម្ដាយ ខ្ញុំ បានបញ្ជូន ខ្ញុំ ឲ្យ ទៅរៀន អក្សរ សៀម នៅ សាលា វត្តបែង ព្រោះនៅជំនាន់នោះ ស្ថិតនៅក្រោមការគ្រប់គ្រងរាជរដ្ឋាភិបាលសៀម ក្មេងទាំងអស់ដែលរស់ នៅក្នុងខេត្តបាត់ដំបងទាំងមូល ត្រូវតែចូល រៀនអក្សរ ជាចាំបាច់ ។ ឪពុកម្ដាយណាលាក់កូនទុក ប្រើ មិនឲ្យ ទៅ សាលា ត្រូវតែទទួលទោសពិន័យ ជាទម្ងន់ ។

នៅពេលដំបូង លោកគ្រូបង្រៀន អក្សរ សៀម បានឲ្យ កុមារ ទាំងអស់ រៀន ច្រៀងគោរព ភ្លេងជាតិ ថៃ ជារៀងរាល់ថ្ងៃ លុះត្រាតែចាំស្ទាត់ រហូតមួយជីវិត តែ ដោយ ខានអនុវត្ត រៀនសូត្រយូរ ខ្ញុំក៏ នៅចាំបានឃ្លាខ្លះ ភ្លេចឃ្លាខ្លះ ។ ក្រោយពីនោះ

លោកគ្រូ ថៃបង្រៀន ឲ្យ រៀនអានអក្សរ កកៃ ខខៃ ... ឲ្យចាំមាត់ រហូតគ្រប់អស់តួព្យញ្ជនៈ និងស្រៈផងដែរ ។

រៀនបានបី–បួនខែ ស្រាប់តែសៀមដកថយពីខេត្តបាត់ដំបង ទៅ ទុកឲ្យសិស្សនៅសោកសៅ ដោយប្រាសចាកនូវដំរេះវិជ្ជា តែមាតាបិតាខ្លះ ត្រឡប់ជារីករាយ ទៅវិញ ។

ក៏ប៉ុន្តែវត្តវែង នៅតែបែងចាំង ក្នុងកម្លាំងបាត់បែង អប់រំវិជ្ជា តាមលំនាំព្រះពុទ្ធសាសនា ជាដរាប ។ ព្រះចៅអធិការ បង្រៀនសិស្ស ដោយផ្ទាល់ ក្នុងការរៀនអាន រៀនសរសេរ ន មោពុទ្ធាយ សិទ្ធំ អ អា ឥ(អានថាអឹក) ឦ (អានថាអី) នៅលើក្ដារឈ្នួនមួយ យ៉ាងវែង ដែលមានឆ្លាក់ អក្សរទាំងនោះ ទុកជាគំរូ ។

ជារៀងរាល់ថ្ងៃ គេពុតែសូរសម្រែកសិស្ស ស្រែកថា ៖
ន អើយ ន ; មោ អើយ មោ ; ពុទ្ធ អើយ ពុទ្ធ... ដើម្បីឲ្យចេះចាំស្ទាត់ ។ ពេលដែលសិស្ស ត្រូវ បំណាយ ដើម្បី បំណាំនូវ បំណេះ ចេះចាំ ចេះអាន និងចេះសរសេរ អក្សរទាំង ១០តួនោះ យ៉ាងតិចមួយខែ ។ សិស្សណាពុំសុវពូកែ ក៏នៅតែព្យាយាមទន្ទេញ តែ ដដែលៗ ។

ពេលយប់ សិស្សត្រូវ រៀន ធម៌សំរាប់ថ្វាយបង្គំព្រះ ព្រមទាំងធម៌សំរាប់បួស ធម៌សំរាប់សូត្រមន្ត ធម៌សំរាប់សូត្រព្រះបរិត្ត ធម៌សំរាប់សូត្រ អាគមគាថា ផ្សេងៗផង ។ល។ និង ។ល។

ពេលថ្ងៃសិស្សដែលវៃវាង ជាងគេត្រូវបាន រៀនអានសាស្ត្រា ឬ គម្ពីរ ឬ ក្រាំង មុនគេ ។

ការរៀនសង់ផ្ទះ ធ្វើរទេះ ចាំងនង្គ័ល ធ្វើរនាស់ និងធ្វើរបស់របរផ្សេងៗ ... ក៏ត្រូវបាន អនុវត្ត នៅសាលាវត្តដែរ ។

ដូច្នេះ សិស្ស សាលាវត្ត មានគុណសម្បត្តិសំខាន់ ក្នុងការ ប្រកបការងារ នៅពេលដែលបានចេញពីវត្ត ឬក៏សឹកពីបួស ។ សិស្សណា ដែលមានប្រាជ្ញាខ្លាំង គេតែងតាំងងារឲ្យជាលោកបណ្ឌិត ឬបើខ្សោយ ឬខ្លៅពិត ក៏គេសន្មតហៅថា ជាលោកអន្ទិត ឬក៏អាអន្ទិត។

វត្ត ជាជម្រក ព្រះសង្ឃ ដែលគង់ចាំវស្សា គាំទ្រ ព្រះពុទ្ធសាសនា គោរពបូជា ព្រះរតនត្រ័យ ផ្សាយធម៌មេត្តា រំលែកធម៌អាថ៌ ដល់ពុទ្ធសាសនិកជន គ្រប់ជាន់ថ្នាក់ ដោយឥតរើសអើងនូវជាតិ ភេទ ភាសា ពណ៌សម្បុរ ។ល។ ជាកន្លែងអប់រំ ជាស្រែបុណ្យ និងជាថ្នាលសំរាប់សាបព្រោះ បណ្តុះ ភាសា និងវប្បធម៌ផងដែរ ។

តែរូបខ្ញុំពុំត្រូវ មានវាសនា នឹងបាន បួសរៀន នៅសាលាវត្ត បែង ក្រោយពីសៀម បានដកថយទៅ ដោយបន្សល់នូវវិជ្ជាកកៃ ខខៃ ទុកឲ្យខ្ញុំបេះផ្លែលែលក ក្នុងការប្រកបការងារ ប្រចាំជីវិត ។

ហេតុនេះ ហើយ បានជាការសិក្សាអប់រំ របស់សៀម បានត្រឹមតែធ្វើឲ្យខ្ញុំ នៅក្រៀមក្រំ យំស្រណោះខ្លួន ជាចៅកកៃ!

## “ចៅស្លឹកចេក”

## ៤

ឆ្នាំ១៩៤៧ ក្រោយពីពេលដែលសៀម បានដកថយ ដោយលែងឃុំគ្រង ខេត្តបាត់ដំបងទៅ ខ្ញុំក៏ត្រូវឈប់រៀនអក្សរសៀម ហើយក៏ក្លាយខ្លួនទៅជា ចៅស្លឹកចេកវិញម្តង។

ថ្ងៃមួយ កុមារគិមស្នួគិ ត្រូវទៅចាំចម្ការ ថែរក្សា ពីព្រលឹមទល់ព្រលប់ មិនឲ្យហ្វូងស្វា មកដកសណ្តែក និងហែកពោតស៊ី ។

ម្តាយខ្ញុំបានខ្ចប់បាយ ប្ហូបបំរុង រៀងរាល់ពេល ព្រោះចម្ការនោះ នៅឆ្ងាយបន្តួរ ពីផ្ទះ ហើយអ្នកចាំចម្ការក៏គ្មានពេលវេលានឹងរំលៀកខ្លួនឲ្យឆ្ងាយ ពីសត្វស្វាទាំងហ្វូងៗ នោះផង ។

មុនទៅដល់ចម្ការ ខ្ញុំត្រូវដើរកាត់ផ្ទះតាស៊ិន យាយចាន់ ។ តាជូនទាំងពីរនេះមានកូនប្រុសកម្លោះចាស់ម្នាក់ ឈ្មោះ សឿន និងចៅស្រីពីរនាក់១ ឈ្មោះ សារួន ១ទៀត

ឈ្មោះសារ៉ាត់ ដែលជាកូនស្រីកំព្រាម្ដាយ ។ ឪពុកនាងទាំងពីរ ត្រូវជាកូនបង្កើតរបស់តាស៊ិនយាយចាន់ ជាប់រវល់រកស៊ីឈ្នួលដើរឡាន នៅឯផ្សារបាត់ដំបង ។ នាងសារួនមានអាយុស្របាលខ្ញុំ។ ថ្វីតែជាកូនកំព្រា តែនាងមានរូបឆោមលោមពណ៌ល្អស្រស់ ។ នាងជាផ្កាមាលតីលាក់ខ្លួននៅក្នុងភូមិកោះអូរស្រឡៅ គួរឲ្យស្រឡាញ់ ។

កុមារគិមស្នួគមាន ពូថៅ ដំបងឫស្សី និងធ្នូព្រួញ គ្រាន់កំញើញនិងបាញ់ស្វា ។ ពេលព្រឹកពុំសូវមានស្វាប៉ុន្មានទេ តែពេលថ្ងៃនិងពេលរសៀល មានស្វាច្រើនណាស់ មានស្វាក្រិស ស្វាត្រោស ចុះពីលើដើមស្វាយ និងដើមឫស្សី មកឲ្យរពុយ ។ ខ្ញុំក៏ប្រថុយតតាំងនឹងវា បើពុំនោះសោតទេមុខតែអស់ផលដំណាំហើយ។ ដំបូងខ្ញុំយកដុំដីគប់ស្វា តែអាស្វាធំ វាញាក់មុខញាក់មាត់ដាក់ខ្ញុំ ពុំព្រមគេចចេញ ឬញញើតសោះ ព្រោះជាក្មេងតូច ។ ខ្ញុំយកដំបងគ្រវែង វានៅតែញាក់មុខតយរជជែល ។ ខ្ញុំក៏ទាញធ្នូយកមកបាញ់ ពេលនេះវាហាក់ដូចជាធ្វើជាបាញ់ខ្ញុំ ហើយរត់ទៅទាំងស្រែកកកោកកកាក ចចេកចចូច បូញមាត់បត់ជុំដៃ អង្រួន មែកស្វាយ ពង្រាយស្លឹក ធ្លាក់រប៉ាត់រប៉ាយ ។

មុនពេលទទួលទានបាយថ្ងៃត្រង់ ខ្ញុំចុះទៅក្នុងអូរ លោតក្នុងទឹកជម្រះខ្លួន ។ គាប់ជួនក្រមាខ្ញុំត្រូវទទឹកជោក ព្រោះរវល់តែគិតដល់ស្វា ខ្ញុំភ្លេចស្រាតក្រមាពីខ្លួន ។ តាមធម្មតា ខំតែងតែងស្រាតក្រមា នៅពេលលោតងូតទឹកម្ដងៗ ព្រោះនៅទីនេះមានតែខ្ញុំ ហើយខ្ញុំក៏ពុំមានទៅខ្មាសអ្នកឯណាទៀតទេ ។ ម្យ៉ាងទៀតខ្ញុំនៅតូចផង បើគេឃើញប្រដាប់បន្តពូជរបស់ខ្ញុំ ក៍ពុំសូវឃើញអ្វីជាអស្ចារ្យណាស់ណាទេ!

ដោយសារក្រមា ត្រូវទទឹកជោក ខ្ញុំត្រូវតែយកក្រមាទៅហាលថ្ងៃ នៅពេលឡើងពីទឹក ។ ទោះបីខ្ញុំ ខំទៅលោតក្នុងទឹកយ៉ាងណា ក៏ពុំស្វាងពីងងុយដេក ពីព្រោះយប់មិញ ខ្ញុំរវល់តែដក់ចិត្តស្ដាប់រឿងរបស់លោកតាស៊ិនដែលបាននិទានពីរឿង៖

"**បក្សីលៀងអារក្ខ**" ។

ដោយសារ ងងុយខ្លាំងពេក ខ្ញុំក៏ប្រាសដេកមួយស្រឡេតនៅក្រោមដើមស្វាយ ។ ពួកស្វានាំគ្នា ចុះមករើកកាយយកកញ្ចប់បាយ មកជកសណ្ដែក ហើយនិងមកយកក្រមាខ្ញុំទៅបាត់ ។ ពេលភ្ញាក់ឡើងទាំងស្រមើងស្រមៃ ខ្ញុំយកដៃជូតភ្នែក ហើយស្រែកថា

អាស្វាបជ្រៃ មកបំផ្លាញដំណាំអញ មកយកបាយអញស៊ី ហើយមកយកក្រមាអញទៅទៀត ។ អស់ពីស្រែកខ្ញុំយំ ព្រោះបាយក៏អស់ សណ្ដែក ក៏សណ្ដក ពោតក៏ពាយ ក្រមាក៏បាត់ !

ដល់ល្ងាច ពេលដែលត្រូវត្រឡប់ទៅផ្ទះវិញ ខ្ញុំពុំដឹងជាធ្វើយ៉ាងណា ដើម្បីឲ្យបានក្រមាមកវិញ ។ ខ្ញុំយំខ្ញុំស្រែក រួចក៏សំរេចថា យកស្លឹកចេកមកស្រោបខ្លួនក្រែងបាត់ខ្មាសបានមួយគ្រា ។ ខ្ញុំក៏យកពូថៅមកសៀតចង្កេះ ទាញព្រួញធ្នូនិងចាប់ដំបងរត់ធ្ងងកាត់ផ្ទះតាស៊ិនយាយចាន់ ។ ទ្រូងខ្ញុំចាប់ផ្ដើមបុកភឹបៗ ដោយភិតភ័យនិងដោយសេចក្ដីអៀនខ្មាស ណាមួយខ្លួនខ្ញុំស្ថិតនៅក្នុងរបុំស្លឹកចេកយ៉ាងដូច្នេះ ណាមួយក្រែងលោនាងសារួន នាងលួចមើលខ្ញុំ ព្រោះរាល់ដងនាងតែងតែបោលក្រសែភ្នែកក្រឡេកមើលខ្ញុំជាញឹកញយ សឹងធ្វើឲ្យធ្លោយស្មារតី ដោយសេចក្ដីញាប់ញ័រ យ៉ាងបំប្រប់ សឹងសន្ធប់ក្នុងវ័យក្មេង។

ខ្ញុំកំពុងតែរត់ផងបន់ផងឲ្យតែគេមិនឃើញខ្ញុំ ក្នុងរមូស្លឹកចេកយ៉ាងនេះ ព្រោះជារឿងគួរឲ្យអាមាស ស្រាប់តែមាសឿនស្រែកសួរ គួរសម មកខ្ញុំថា ៖ អាឈ មានរឿងអ្វី កំប្លែងបានជាឯងក្លាយទៅជាចោស្លឹកចេក? (សូមជំរាបថា ទាំងម្ដាយ ទាំងឪពុក ទាំងបងប្អូន ទាំងមីងមា ទាំងអ៊ុំ អ្នកស្រុកទាំងអស់ រមែងហៅឈ្មោះខ្ញុំថា អាស មានតែមាខ្ញុំម្នាក់ឈ្មោះប្រុប គាត់ហៅខ្ញុំថា អាឈរ ឈ្មោះ សួគ៌ គឺនៅពេលដែលខ្ញុំបានចូលរៀននៅសាលាវត្តបុប្ផារ៉ាម នៅថ្ងៃដំបូង )។

ខ្ញុំចេះតែប្រឹងរត់ បិទមាត់ដូចគេបុក ខុសពីពេលធម្មតា ដែលខ្ញុំតែងតែរក្សាការគួរសមនឹងចាស់ទុំ ឬក៏ជាមួយនាងសារួន ឬនាងសារ៉ាត់ ផងដែរ ។

ពេលរត់ទៅដល់ផ្ទះ ខ្ញុំក៏ស្រែកយំង៉ោង រួចហើយក៏អណ្ដឹតអណ្ដក ព្រោះពុំដឹងជានិយាយប្រាប់ឪពុកម្ដាយបិញ្ចឹមរបស់ខ្ញុំថាដូចម្ដេច បើ “សណ្ដែកក៏សណ្ដក ពោតក៏ពាយ ពោះក៏ឃ្លាន ក្រមាក៏បាត់ ! ”

-ម្ដាយបិញ្ចឹមខ្ញុំ ស្រែកសួរមកខ្ញុំថា ៖ ចុះម៉េចហើយអាស៊ិ !

-ខ្ញុំគិតតែពីយំ ។ យំដោយខ្ញុំខ្មាស យំដោយខ្ញុំខ្លាចត្រូវរំពាត់ យំដោយខ្ញុំខឹងនឹងស្វា ហើយដោយខឹងនឹងខ្លួនឯង ។

-ម្ដាយខ្ញុំសួរ ហើយសួរទៀត ទៀតហើយទៀតសួរ ។ តែនៅតែគ្មានចម្លើយ គួរឲ្យអស់ចិត្ត ។

- ទីបំផុត ទើបខ្ញុំ ខំបញ្ចេញ សំឡេង ក្រង៉ូវថា ៖ “ខ្វាដកកាដែក! ” គឺថា ស្វាដកសណ្ដែក ព្រោះខ្ញុំនិយាយមិនច្បាស់ នៅពេលនោះ ។

-ម្ដាយខ្ញុំ អស់ពីខឹង និងពីភ័យ ក៏ទៅជាចង់សើច ព្រោះ គាត់ឃើញខ្ញុំយកស្លឹកចេក មករុំខ្លួន ប្រៀបដូចជាចៅស្រទបចេក ក្នុងរឿងព្រេង ។ ម្យ៉ាងទៀត ដោយគាត់ឃើញទឹកមុខខ្ញុំស្លេកស្លាំង ព្រោះត្បិតឥតទាន់បានបាយទទួលទានសោះ គាត់ក៏តាំងទៅជាស្រណោះអាណិតខ្ញុំ ហើយគាត់លួងលោមខ្ញុំឲ្យឈប់យំទៅ ។ ក្រោយពីម្ដាយខ្ញុំបាននាំខ្ញុំឲ្យទៅមុជទឹកពាង គាត់ក៏ទៅសារុងថ្មីស្រឡាងមកឲ្យខ្ញុំស្លៀក ដោយទុកជង់ខ្លួននៅទទេ ព្រោះនៅស្រុកស្រែគេពុំចូលចិត្តពាក់អាវទេ ព្រោះម្យ៉ាង វាក្ដៅស្អុះផង ម្យ៉ាងទៀតដោយ ត្បិតត្បៀតនូវសំលៀកបំពាក់ផងក៏ពុំដឹង ព្រោះជីវភាពអ្នកស្រែចម្ការពុំសូវជាធូរធា ណាស់ណាទេ ។ រួចហើយ គាត់ក៏ទៅជួសបាយ ព្រមទាំងសម្លប្រហើរ ដែលបង់ប្រហុកយ៉ាងឆ្ងុយឆ្ងាញ់ មកឲ្យខ្ញុំបរិភោគ ជាមួយនឹងឪពុកម្ដាយបិញ្ចឹម យ៉ាងញញឹមញញែម ក្លែមនឹងប្រហុកដុត ហុតសម្ល ដំក្រៀមក្រោះ អស់បាយដែលក្ដាយពីអង្ករបុកដៃ ទាំងចានៗ មានកម្លាំងប្រឹស ដោយត្រលាស់ ត្រលៀវ អណ្ដាត ត្រវាត់ភ្លែមៗ ភ្លក្សរសជាតិ យ៉ាងវវះវវាម ដូចជាគេលើកម្រាមដៃឡើងរាំ ។

ដំណឹងស្វាដកសណ្ដែក ឬ “ខ្វាដកកាដែក” នេះ ក៏លេចឮដំណឹងទៅដល់ម្ដាយ ឪពុកម្ដាយ និងបងប្អូនបង្កើតរបស់ខ្ញុំ ហើយគេនាំគ្នាហៅខ្ញុំថា “អាខ្វាដកកាដែក ឬ ចៅស្លឹកចេក ” ជាប់រហូតមក ។

## ចៅគង្វាលគោ

ឆ្នាំ១៩៤៨ ចាប់ពីថ្ងៃដែលសត្រូវបានយកក្រមាខ្ញុំទៅបាត់ ម្ដាយឪពុកខ្ញុំលែងប្រើខ្ញុំឲ្យទៅចាំចម្ការទៀតហើយ ។ គាត់ប្រើខ្ញុំឲ្យទៅឃ្វាលគោវិញម្ដង ។ ក្នុងការងារថ្មីនេះ ខ្ញុំហៅសែនមហាសប្បាយរីករាយអស្ចារ្យ ព្រោះខ្ញុំមានគ្នានាក់ទៀតចូលមករួមចំណែក គឺអាឡុក ដែលទើបនឹងត្រូវឪពុកម្ដាយចិញ្ចឹមខ្ញុំ សុំយកមកធ្វើជាកូនចិញ្ចឹមដូចខ្ញុំដែរ ។ អាឡុកជាកូនមាម៉ែនមីងនឹម ។ គ្រួសារនេះជាអ្នកក្រខ្សត់រត់ជាមួយនឹងគូកនម្នាក់ទៀតឈ្មោះពុត-វ៉ាន់ មកពីខេត្តស្វាយរៀង ។ គាត់ទាំងពីរគ្រួ ជាកូនឈ្នួលលោកយាយអឿម ដែលត្រូវជាម្ដាយក្មេក ម្ដាយបង្កើត របស់លោកឡូ-ស៊ីន ដែលជាអ្នកកាន់ធម៌អាចារ្យ រក្សាសីលទាន មានព្រលឹងរស់នៅដល់សព្វថ្ងៃនេះ នៅស្រុកបារាំង ត្រង់ម្ដុំទត្តសង្ឃ ។

មាម៉ែន មីងនឹម មានកូន ៤នាក់ ។ មាពុត មីងវ៉ាន់មានកូន២នាក់ ។ មាម៉ែនមីងនឹម គាត់បានមកសុំដីឪពុកម្ដាយចិញ្ចឹមខ្ញុំ ដើម្បីរស់នៅ ។ មាពុត - មីងវ៉ាន់បានសុំដីទំនេររបស់មាម៉ុច ដើម្បីស្នាក់នៅ ។ ៤នាក់ នាងយេន នាងយ៉ាន អាឡុក អាផល( អាផលជាកូនសំណព្វនិងសំណល់ផលបុងក្រោយពីជំងឺផ្កាឈើ) ត្រូវជាកូនរបស់មាម៉ែន និងមីងនឹម ។ ២ នាក់ នាងគិន និងនាងខ៊ែត ត្រូវជាកូនរបស់មាពុតនិងមីងវ៉ាន់ ។

ទាំងពីរនាក់ អាឡុកនិងខ្ញុំស្ទុះក្រោក ពីព្រលឹម ក្រោយពីបានទទួលបាយកញ្ចប់ និងទឹកបំពង់ហើយ ក៏ទៅស្រាយកូនគោស្ទាវមួយម្នាក់ ដឹកចេញពីក្រោលសំដៅទៅវាលស្រែ ។ គោខ្ញុំ ជិះបានសម្បុរលឿងចាស់ ឈ្មោះវាអាកំបុត ព្រោះវាមានស្លឹកត្រចៀក កំបុតម្ខាង ។ គោអាឡុក ជិះមិនបានទេ នៅពេលដំបូង សម្បុរខ្មៅ រាងអោនរុលទៅមុខ ក្រផុល ហៅថា អាផោល ។

មុននឹងចេញដំណើរ ទាំងពីរនាក់ រង់ចាំអាយ៉ម ដែលត្រូវជាកូនអ៊ុំរិន-ឡេង ជិះគោមួយ ដឹកគោមួយទៅឃ្វាលដែរ ។ អាយ៉ម មានអាយុ បងខ្ញុំមួយឆ្នាំ តែវាមានកម្លាំងពលំមាំមួនណាស់ ។ អាឡុក មានអាយុ ជំណាលគ្នានឹងខ្ញុំ ។

វាលស្រែនៅឆ្ងាយ ពីផ្ទះប្រហែល ពីរគីឡូម៉ែត្រ តែខ្ញុំជិះលើខ្នងគោ បានធូរជើងជាងអាឡុក។ យើងត្រូវ ឆ្លងកាត់អូរ ដើម្បីទៅកាន់ វាលស្រែ ព្រោះយើងរស់នៅលើភូមិកោះ ។ នៅរដូវវស្សា យើងត្រូវតែហែលឆ្លងទឹក ទាំងមនុស្សទាំងគោ ហើយយើងធៀតហក់លើខ្នងគោម្តងៗ ដើម្បីបង្ហាត់គោសំរាប់ជិះទៅថ្ងៃមុខ ។ ហេតុដូច្នេះ បានជាយូរថ្ងៃទៅ ទោះគោផ្លាង យ៉ាង ក៏អាចជិះបានទាំងអស់ ។

នៅពេលដែលឆ្លងអូរ យើងធៀតកេះដីឥដ្ឋទន់ៗ ឲ្យបាន មួយដុំម្នាក់ ដើម្បីយកទៅទុកលុញគ្រាប់កៅស៊ូបំពាម សំរាប់បាញ់សត្វ ។

ពេលទៅដល់វាលស្រែ ពួកយើងលែងគោឲ្យដើររកស៊ីស្មៅ តាមតែចិត្តវាទៅ ព្រោះអីទីវាលធំទូលាយណាស់ រាប់រយហិកតារ ហើយមានតែស្មៅដុះល្វឹងល្វើយ ។

យើងទាំងបីនាក់នាំគ្នាលុញគ្រាប់ មូល ដាក់ហាលថ្ងៃបណ្តើរ លុះត្រាតែអស់ដីឥដ្ឋ រៀងៗខ្លួន ហើយគ្រាប់ដែលលុញមុនគេ ក៏ស្ងួតល្មម រួចក៏នាំគ្នារើសគ្រាប់រឹង ទៅដើរបាញ់ ចាប ពពេច លលក ក្រួច និងសត្វអ្វីឲ្យតែប្រទះ ទោះទន្សាយ ពស់កំប្រុក សំពោច រីក ត្រលិងត្រលោង សេក ...។ល។... សត្វមានច្រើនណាស់ តែខ្ញុំបាញ់ដែលបានមួយឡើយ អាយ៉ម វាពូកែបាញ់សត្វណាស់ អាឡុកក៏ ដូចខ្ញុំដែរ គឺឃាតែក្អួប បានចាំតែស៊ីសាច់សត្វដោយសារអាយ៉ម ។ បើអាយ៉មបាញ់មិនបានទេ មុខតែស៊ីបាយកញ្ចប់ជាមួយនិងប្រហុកដុត ឬ ជាមួយនិងត្រីកញ្ចុះ ដុតហើយ ។

ក្រោយពីបាញ់សត្វ យើងទាំងបីនាក់ ក៏មាន ស៊ឹង ឬ សំណាញ់ សំរាប់ដាក់អន្ទាក់ក្រួច ដែរ។

នៅពេលថ្ងៃត្រង់ ទើបយើងនាំគ្នា ទៅរកចាប់គោ មកឲ្យផឹកទឹក និងចងឲ្យវាជ្រកម្លប់ ដេក សំរាក ទាំង គោ ទាំង ម្ចាស់ ។ ដល់ ពេលថ្ងៃ រសៀលទើបលែងគោឲ្យទៅរកស៊ីស្មៅទៀត។ ភារៈកិច្ចរបស់យើង ធ្វើរបៀបនេះ ជារៀងរាល់ថ្ងៃ ដដែលៗ ។ ដូច្នេះវាមិនធ្ងន់ធ្ងរទេ ជីវិតក្មេងឃ្វាលគោ ។ តែជាជីវិត ជាប់ប្រឡាក់ប្រឡូស ដោយដី

ធ្វើ យ៉ាងស្រមកស្រមេះ ធំក្លិនធ្អេះដោយ ក្លិនគោ ជាប់ជានិច្ច លុះត្រាតែភ្លេចអស់ទៅ ដោយ ស៊ាំប្រមុះ អស់ ទៅ ហើយ ។ រីឯ សេចក្ដីសប្បាយ ហៅ សែន មហា សប្បាយ រីករាយ អស្ចារ្យ ។ ក្មេងគង្វាលគោ ប្រៀប បាន ដូច ជា ស្ដេច គឺ ស្ដេច គ្រប់គ្រង គង្វាល សោយរាជ្យ នៅលើរាជវាំងវាលស្រែ ហែហម អម ដោយ គោក្របី ម្រឹគម្រឹគា បក្សី បក្សា ខ្សៀវខ្សារ ច្រៀងរាំ បន្លឺ បទភ្លេង យ៉ាងក្រអៅ នៅ ក្នុងជម្រៅ ព្រៃព្រឹក្សា ជំ មាន សេរីភាពយ៉ាងក្លៀវក្លា ហ៊ឺហាជាងសឹង ខ្លា គោជាប់ទ្រូង ដែលគេបំរុងនឹងយក ទៅ សំដែង ល្បែង សៀក ទៅ ទៀត ។

## ចៅចំណងព្រះ

## ៤

បុងឆ្នាំ១៩៤៨ ព្រឹកមួយ ក្រោយ ពីបាន ទៅ ឃ្វាលគោ ជាង៣ខែ ស្រាប់តែ ម្ដាយ ខ្ញុំ ប្រាប់ខ្ញុំថា ចូរ ឯង ទៅ ឃ្វាល គោ តែ ម្នាក់ ឯងចុះ ព្រោះ អាឡុក វា ស្លាប់ហើយ !

ខ្ញុំ ភ្ញាក់ ព្រើត ព្រឺអស់ខ្លួន ប្រាណ ព្រោះ យប់ មិញ ខ្ញុំ ដេក ជិត វា សោះ វាគ្រាន់ តែគ្រុន ស្រីវស្រាញ បន្តិច បន្តួច ។

ខ្ញុំ ក៏ ទៅ ស្រាយ គោ ទាំង ពីរ ពីក្រោល ដឹកទៅកាន់ វាល ស្រែ ជាមួយនឹងអាយ៉ម ដូចសព្វមួយដង ដោយទឹកភ្នែក រលេងរលោងរលីក នឹកស្រណោះដល់អាឡុកជាពន់ពេក !

មច្ចុរាជ បានបន្សល់ជីវិតគ្រប់គង្វាល នៅសល់ តែពីរនាក់ ។ ឥឡូវអាយ៉ម និងខ្ញុំ ប្រៀបបានដូចជា លលកញីឈ្មោល ដែលពុំដឹងជាថ្ងៃណា ត្រូវព្រានផ្ដាច់សង្វារ បំបែក ពីគ្នា ម្ដងមួយៗ ទៀតទេ?

នៅតាមផ្លូវ ខ្ញុំតែងតែ យកកន្សែងមកជូតទឹកភ្នែក ជាលំដាប់ ។

ថ្ងៃនេះ យើងទាំងពីរនាក់ភ្លេច គេះជីឥដ្ឋ ភ្លេចអ្វីៗទាំងអស់ ដែលធ្លាប់បាន ធ្វើឲ្យ យើងសប្បាយរីករាយ ។

យើងត្រឡប់មកផ្ទះវិញ មុនពេលព្រលប់ !

ចាស់ៗ បានយកខ្មោច អាឡុកទៅកប់បាត់ហើយ ដោយប្រញាប់ប្រញាល់ ដាទីបំផុតៗ មិនគ្រាន់តែកប់ខ្មោច អាឡុកទេ គឺកប់ទាំងខ្មោច នាងយេន និងនាងយ៉ាន ផង ក្នុងផ្នូរ ទាំងបីទន្ទឹមគ្នា !

មាម៉ែន និងមីងទឹម គាត់យំសោកបោកខ្លួន ៗ ចុះហេតុអ្វី ផលអ្វី ក៏មកជួបជួនគ្នា នៅថ្ងៃតែមួយយ៉ាងដូច្នេះ? តើចិត្តនរណា មិនរញ្ជួយ ជួយអាណិតក្មេងទាំងបី ដែលត្រូវជាចំណីបច្ចុរាជ ដោយខ្មោចផ្សាយ៉ាងនេះ !

រឿងហេតុ ដែលបណ្តាលឲ្យស្លាប់យ៉ាងស្រស់ៗ យ៉ាងនេះ គឺមកអំពីជំងឺឆ្លងហៅថា អុត តែអ្នកស្រុក មិនហ៊ាន ហៅឈ្មោះជំងឺនេះចំទេ គេបង្វែរឈ្មោះជាជំងឺផ្កាឈើទៅវិញ ព្រោះវាកាចសាហាវណាស់ ៗ ជាងកន្លះ ខែមុន វាបានផ្តាច់ជីវិតបងយ៉ន ដែលត្រូវជាកូនស្រីបិញ្ចឹមរបស់ឪពុកម្តាយ បិញ្ចឹមខ្ញុំដែរ តែខ្ញុំភ្លេចជំរាប លោកអ្នកអាន ព្រោះគាត់ បាន ទៅរស់នៅឯទីផ្សារ ជាមួយ នឹងគូកំណាន់ចិត្ត ឈ្មោះឈុកដែល ទើបនឹងមកពីស្រុកឯជើង (គេហៅថាស្រុកឯជើង ដោយចង់សំដៅថាក្រុងអង្គរ ព្រោះក្រុងអង្គរស្ថិត នៅខាង ជើង ខេត្តបាត់ដំបង) មកធ្វើជាគូលី ជីកអណ្តូង ឲ្យឪពុក ម្តាយ បិញ្ចឹមខ្ញុំ តែមិនបានប៉ុន្មានថ្ងៃផង ក៏ជម្រត់បងស្រីខ្ញុំទៅបាត់ ៗ ដល់មានជំងឺជម្កាត់ បងស្រីខ្ញុំ ក៏វិលមកព្យាបាលជំងឺ នៅឯអូរស្រឡៅវិញ តែបានត្រឹមតែនាំជំងឺ មកចម្លងរាលដាលពេញទាំងភូមិ !

បើគេរាប់ពីលិចទៅកើត បន្ទាប់បន្តិចពីផ្ទះឪពុកម្តាយ បិញ្ចឹមខ្ញុំ ទៅគឺខ្ទមមាម៉ែន មីងទឹម រំលងរបង គឺផ្ទះមាម៉ាន់ មីងអ៊ិត (ឪពុកម្តាយរបស់បងមឿន បងស្រីតាន់នាងផារ៉ាន នាងផារេន នាងផារឿយ អារ៉ូន អារឿង) ខ្ទមមាពុតមីងវ៉ាន់ ផ្ទះអ៊ុំរិន អ៊ុំឡេង (ឪពុកម្តាយរបស់បងស្រីឡេន អាយ៉ម នាងរ៉ុន) ឆាកត្បូងបន្តិច ខ្ទមពូឆេង កម្លោះចាស់ រួចឆ្ងាយបន្តិចគឺផ្ទះមាប្រុច មីងលាង ហើយខាងកើតបំផុតដល់មាត់អូរ គឺខ្ទម មាឌួង មីងលិន (ឪពុកម្តាយរបស់នាងសារ៉ែន នាងឡឿង និងនាងវ៉ាន់ឌីៗ វ៉ាន់ឌី ជាកូនមីងលិនជាមួយ មាឌួង ពីរនាក់មុន ជាកូនជាមួយប្តីមុនឈ្មោះរិក)ៗ

កូនក្មេងទាំង១៩នាក់ ទទួលជំងឺឆ្លង ៨ នាក់ គឺ៖ (ស្លាប់ ៤ នាក់) គឺ បងយ៉ន នាងយេន នាងយ៉ាន អាឡុក(មើលជា៤នាក់ តែនៅមានស្នាមបន្សល់ទុក ពេញមុខ ពេញខ្លួន) គឺបង

គាន់ នាងផារ៉ាន ផាឡើយ និងនាងឡឿង ៧នាក់ទៀតមានវាសនាខ្ពស់ មិនកើតជំងឺអុត ពីព្រោះ បើតាមការគន់គូររបស់អ៊ុំទ័ន ថាអ្នកទាំងនោះមាន ចំណងព្រះ នៅត្រង់កន្ទាក់ដៃ គឺ រូបខ្ញុំ បងមឿន នាងផាអេន អារុន អាវឿង នាងសារ៉ែន និងនាងខ៊ាន់ឌី ។

គ្មានក្មេងណា ថាមិនភ័យទេ កំប៉ុន្តែពិត ជាគេបេះតែ ព្រួយ ហើយខ្លាចនូវអំណាច ជំងឺផ្កាឈើនេះណាស់ យ៉ាងផ្អែមមាត់ និងស្ងប់ស្ងាត់ បាត់មាត់ បាត់ក !

## ចៅឆខ្វាក់

## ៤

ឆ្នាំ១៩៤៩ ក្នុងអាយុ បាន១១ឆ្នាំ ខ្ញុំជាក្មេងរត់លេង យ៉ាងសែនសប្បាយណាស់ ពីផ្ទះមួយទៅផ្ទះមួយ នៅក្នុងភូមិកោះអូរស្រឡៅ ព្រោះខ្ញុំមាន អ៊ុំប្រុស អ៊ុំស្រី មា មីង ជាច្រើន ។ បើខ្ញុំមិនទៅផ្ទះ អ៊ុំទ័ន អ៊ុំឆួន គឺខ្ញុំទៅផ្ទះ មាប្រូច មីងឈាង ។ បើខ្ញុំមិន នៅផ្ទះមាប្រូច មីងឈាង គឺខ្ញុំនៅផ្ទះមាម៉ាន់មីងអ៊ិត ។ បើខ្ញុំមិននៅផ្ទះមាម៉ាន់មីងអ៊ិត គឺខ្ញុំ នៅផ្ទះអ៊ុំរិន អ៊ុំឡេង ... គឺម្ដងខ្ញុំនៅផ្ទះអ្នកនេះ ម្ដងខ្ញុំនៅផ្ទះអ្នកនោះ ដែលត្រូវជា សាច់ញាតិ ឪពុកម្ដាយ បិញ្ចឹមខ្ញុំ គាត់សុំសូវជាខ្វល់នឹងរកខ្ញុំ ទេ ព្រោះស្រឡាញ់ ហើយបណ្ដោយខ្ញុំឲ្យដើរលេងតាមចិត្ត ដោយគាត់រឹតតែអាណិតខ្ញុំ តាំងតែពីខ្ញុំ ក្លាយខ្លួនជា ប៉ោស្វឹកបេកមកម៉្លេះ ព្រោះគាត់បេះតែនឹកស្រមៃទៅដល់ប៉ោស្រទបបេក ដែលគួរ ឲ្យសង្វេគ និងអាណិតអាណោច ជាពន់ពេក !

នៅពេល ដែលខ្ញុំបេះតែដើរ ម្ដងទៅផ្ទះមីងនេះ ម្ដងទៅផ្ទះអ៊ុំនោះ ដំបូងម្ដាយ ខ្ញុំបេះតែហៅរកខ្ញុំឲ្យមកទទួលទានបាយ ដល់យូរទៅ ដោយមីង ឬអ៊ុំ បេះតែឆ្លើយ ប្រាប់ម្ដាយខ្ញុំថា អាសី វាស៊ីបាយរួចហើយ ជាញយដង ម្ដាយខ្ញុំ ក៏លែងហៅរកខ្ញុំឲ្យ មកទទួលទានបាយទៀត ព្រោះគាត់យល់ថា មានមីងមា និងអ៊ុំប្រុសអ៊ុំស្រី ជួយ បិញ្ចឹម បីបាច់ថែរក្សា ទៅហើយ ។ ខ្ញុំក៏ក្លាយទៅជាក្មេងទំរើស ។

កាលបើអ៊ុំ មីងមា ស្រឡាញ់ហើយ ក្មេងក្មាងធំតូច ក៏ស្រឡាញ់រាប់ខ្ញុំដាងគេ ។

នៅពេល លេងប្រឡែងតាមល្បែងក្មេង គ្មានក្មេងណា ខឹងនឹងក្មេងណាទេ ។ តែបើលោ ជាមាន ក្មេងណាប្រកាន់ខឹង ក្មេងដទៃទៀត តែងតែស្រែក ច្រៀង ចំអកថា៖ “ខឹង យកកណ្តឹងចងក...” ។ ពុំតែដើមឃ្លាតែប៉ុណ្ណោះ ក្មេងដែលកំពុងតែខឹង ក៏បាត់ខឹងភ្លាម ព្រោះខ្លាចគេបន្ថែមឃ្លាទៀត ដែលនាំឲ្យរឹតតែខ្មាសអៀន ។

សប្បាយ នៅវ័យក្មេង គឺសប្បាយលែងបើគិត ។

បើខ្ញុំចង់ញ៉ាំ បបរក្តៅៗ ជាពិសេស បបរខ្ទិះដូង ខ្ញុំ តែងតែទៅលេងផ្ទះអ៊ុំរិន និងអ៊ុំឡេង ព្រោះអ៊ុំឡេង ចូលចិត្តធ្វើបបរណាស់ ។ គេញ៉ាំបបរជាមួយនឹងស្ករត្នោត តែផ្ទះអ៊ុំ ឡេងពុំមាន ស្ករត្នោតគ្រប់គ្រាន់ទេ គាត់តែង តែប្រើអាយ៉ម ទៅកាត់ធាង ម្នាស់យក មកចិត្តធ្វើជាស្ករត្នោត សំរាប់ញ៉ាំបបរ ព្រោះជំនាន់នោះ គាត់ក្រស្ករត្នោតណាស់ តែបើនិយាយ ពីផ្ទះវិញ គ្មានផ្ទះនរណាធំជាង ផ្ទះអ៊ុំរិននិងអ៊ុំឡេងទេ គឺជាផ្ទះឈើប្រក់ក្បឿង ក្រោពីផ្ទះជីតាខ្ញុំ ដែលគាត់បានលក់ ទាំងដីទាំងផ្ទះ ឲ្យទៅឲ្យមានៀម និងមីងសយ ដែលថ្ងៃក្រោយ គាត់រុះរើយកទៅសង់នៅឯភូមិវត្តគរទៅ ។

មាម្រួម ជាប្តីរបស់ មីងឈាខ ។ គាត់ធ្លាប់ធ្លាប់ធ្វើ ប៉ោយប៉ារ៉ាំង ។ ដល់បាន មីងខ្ញុំ ជាប្រពន្ធ ដែលមានរូបរាងស្អាតសង្ហារ ដែលជាកូន កាត់ចិន–ខ្មែរ គាត់ក៏លះបង់ មុខរបរធ្វើប៉ោយប៉ារ៉ាំងទៅ ហើយមករស់នៅឯភូមិអូរស្រឡៅ ។

មីងឈាខប្រសប់ ដាំបាយ ឲ្យមានក្តាំងណាស់ ព្រោះគាត់ មានឆ្នាំង ពិសេសជាងគេ នៅក្នុងភូមិ គឺឆ្នាំង ធ្វើអំពីធាតុអាលុយមីនីញ៉ោម អ្នកភូមិភាគច្រើនមានឆ្នាំងដីម្តាយ បិញ្ចឹមខ្ញុំមានឆ្នាំងលង្ហិន។ មុនពេលដាំបាយ ខ្ញុំសង្កេតឃើញ មីងខ្ញុំ យកខ្លាញ់ជ្រូក យកទៅជូតបាតឆ្នាំង ដាំឲ្យឆ្នាំងក្តៅ បន្តិច ទើបគាត់ ចាក់ទឹក ដាំឲ្យពុះ រួចគាត់ លាងអង្ករ ប្រក ក្នុងឆ្នាំងទៅ លុះអង្ករ រលួយរីក ផុយបន្តិច គាត់ក៏សម្រិតទឹកបាយចេញ ហើយក៏ផ្សំបាយទៅ ។

កាលណាខ្ញុំចង់ ទទួលទាន បាយក្តាំង ដើម្បីឲ្យ បានរឹងកម្លាំងធាតុ ខ្ញុំ តែងតែទៅលេងផ្ទះ មាប្រុប និងមីងលាង ។ យូរៗមាប្រុប គាត់នាំមីងខ្ញុំទៅលេង ឯផ្សារបាត់ដំបងម្តងៗ ខ្ញុំតែងតែសុំ គាត់ទៅជាមួយផង ក្រែងនឹងបាន ជួប ឪពុក ម្តាយ និង បងប្អូន បង្កើតរបស់ខ្ញុំ ។

នៅពេលជួបជុំឪពុកម្ដាយ និងបងប្អូន ខ្ញុំតែងបាននុំប៉ាតុងគោ និងនុំបាខ្វៃ ពីម្ដាយខ្ញុំ យកមកឲ្យខ្ញុំទទួលទាន ដោយមានកម្លាំងប្រីស ។ នៅអូរស្រឡៅ ពុំសម្បូរទៅដោយ នុំនេក អ្វីទេ កាលជំនាន់នោះ មានតែបេកអំពៅ និងផ្លែឈើផងទាំងពួងទៅវិញ ។

បើខ្ញុំចង់ញាំ សម្លកកូរ ជាមួយបាយស ឬបាយលិង ខ្ញុំតែងតែទៅលេងផ្ទះ មាម៉ាន់ និងមីងអុិត ព្រោះគាត់ពូកែធ្វើ ម្ហូប ម្ហា ឲ្យឆ្ងាញ់ ពិសា ក្នុងមុខជំនាញការនេះ ។ មីងខ្ញុំរមែង ហៅ ប្ដីគាត់ថា ពុក អាង៉ា ។

ខ្ញុំសួរមាខ្ញុំថា ហេតុអ្វីបានជាមីងហៅមា ថាពុកអាង៉ា?

-ឯងធ្លាប់ឮគេថា កុយពុកឬទេ? (មាខ្ញុំសួរ) ។

-ខ្ញុំឆ្លើយទៅគាត់វិញថា ទេ!

-ចុះរឿងនេះវាយ៉ាងណាដែរ? (ខ្ញុំសួរ)។

កុយពុក គឺកុយរមាស ដែលវាកាច់បោល លាក់ទុកនៅក្នុងដើមឈើ ឬ ក៏ក្នុងដំបូក ឬក្នុងរូងថ្ម ។ កុយនោះ បើអ្នកណា រកឃើញ រើសបាន នឹងយកមកប្រើ ធ្វើជាថ្នាំ ព្យាបាលរោគ លើកកម្លាំង ឬក៏យកមកដំណាងតាំងសំណាកសក្ការៈបូជា នឹងបាន ពូកែ និងសក្ដិសិទ្ធិណាស់ ។ ពាក្យថាពុក ប្រៀប បាននឹងកុយពុកនោះឯង ។

ពុកអាង៉ាប្រែថាកុយពុក ដែលទុកសំរាប់បង្កើតអាង៉ានោះឯង។

មាម៉ាន់ មានដើមកំណើត ជាជនជាតិចាម ។ គាត់បាន ធ្វើទាហានបារាំង មុននឹងបានមីងខ្ញុំធ្វើជាប្រពន្ធ ។ គាត់មានស្ថានភាពស្គុកស្គម្ភ មាំមួនណាស់ ។ គាត់មានកម្លាំងខ្លាំងក្លា ។ គាត់បាន បញ្ចិះ ខ្ញុំដាក់លើស្មា ដើរយ៉ាងសង្ហារ ពីផ្សារបាត់ដំបង មកកាន់ភូមិអូរស្រឡៅ ដោយគ្មានសោកសៅ នឿយហត់ អ្វីបន្តិចបន្តួចសោះ ។ តែថ្ងៃក្រោយពុំគួរសុខភាពរបស់គាត់ បែរជាថយខ្សោយ ទៅជាពិការខ្វិន នៅតែមួយកន្លែង ។

ចំពោះអ្នកខ្លះមានយោបល់ថា មកពីគាត់ត្រូវបានធ្លងគ្រោះមួយដ៏ទម្ងន់ ដោយពួកទាហានបារាំង នៅប្រចាំប៉ុស្តិ៍ក្នុងរ៉ា អូរស្រឡៅ ចាប់យកគាត់ទៅវាយ សួរចម្លើយ ដោយបញ្ចុកទឹកត្រី ក្នុងការឈ្លបរកដំណឹង ពីរឿងលាក់បំពួនខ្មែរឥស្សរៈ ដែលបះបោរប្រឆាំងនឹងបារាំងនៅពេលនោះ ។

ម្យ៉ាងទៀត ដោយសារគាត់ពុំដែលបេះទៅទីណាឆ្ងាយ រវល់តែនៅតែកកាយស្រះ ចាំផ្ទះ ជីកអណ្ដូង និង ប្រូងជំណាំ ដាំដុះផ្សេងៗ នៅក្បែរផ្ទះ ទុកឲ្យមីងខ្ញុំ រូតរះទៅរកស៊ីលក់ដូរនៅទីឆ្ងាយ ដល់យូរទៅវាក្លាយជាពិការ យ៉ាងដូច្នេះឯង ។

មាម៉ាន់ មីងអ៊ិត បាន លាចាកលោកទៅ បានបន្សល់នូវកូនស្រីបីនៅស្រុកខ្មែរសព្វថ្ងៃ ម្នាក់ស្លាប់ទៅហើយ ឈ្មោះនាងផារឿយ ពីរនាក់ទៀត មានជីវិតរស់នៅឡើយ គឺនាងតាន់និងនាងផារេន។ កូនស្រីគាត់ម្នាក់ទៀតឈ្មោះនាងផារ៉ានបានភៀសខ្លួនទៅកាន់សហរដ្ឋអាមេរិកជាមួយប្ដីឈ្មោះសេខ កូនស្រីឈ្មោះរ៉ិច ប្អូនប្រុសឈ្មោះរ៉ូន និងបងថ្លៃស្រីឈ្មោះឈឿមទាំងកូន ព្រមទាំងបងថ្លៃស្រីឈ្មោះដេរ ម៉េម៉ាយពីបងប្រុសឈ្មោះមឿននាំកូនទាំងសំបុក មកសម្រុករស់នៅ ជុំកូនជុំចៅ នៅស្រុកអាតាំងដែរ ។ អារ៉ូនសព្វថ្ងៃក៏ក្លាយទៅជាតាំងជើងដៃ ខ្វិនខ្វៃៗ ហាក់បីដូចជាមាម៉ាន់ដែរ ប្រហែលមកពីជំងឺចម្លងសួរពូជ ឬមួយយ៉ាងណា ក៏មិនដឹង?

បើខ្ញុំចង់ញ៉ាំ បាយជាមួយនឹងសម្លខ្ទិះ ឬអាម៉ុកខ្ទិះ ឬប្រហុកខ្ទិះ ខ្ញុំតែងតែទៅលេងផ្ទះ អុំ ទ៊ន និង អុំឆ្លួន ព្រោះអុំឆ្លួនគាត់ប្រសប់ធ្វើម្ហូបទាំងនេះណាស់ ហើយអុំទ៊ន ក៏ប្រសប់ ទៅប្របក់បានត្រីរ៉ស់ធំៗ ផង ។

អុំទ៊ន ត្រូវជាប្ដីទីពីររបស់អុំឆ្លួន ក្រោយពីប្ដីទី១ បានលែងលះគ្នាទៅ ដោយបន្សល់នូវកូនប្រុសពីរនាក់ គឺលោកបងឆមនិងអាទី។

លោកបងឆមទើបនឹងសឹកពីបួសនេន គាត់បេះសរសេរអក្សរល្អណាស់ ។ អាទីអាយុបងខ្ញុំពីរឆ្នាំ តែខ្ញុំហៅវាអា តែវាឥតប្រកាន់នឹងខ្ញុំដែរ ។

បងឆមសព្វថ្ងៃ បាន ចូលបួសបម្រើសាសនាវិញ ក្នុងឋានៈជាចៅអធិការប្រចាំវត្តថ្មី អូរស្រឡៅ ខាងលិចវ៉ា រទេះភ្លើង។

អុំទ៊ន និងអុំឆ្លួនមានកូន ពៅមួយឈ្មោះ អាឃុខ។

អុំ ទ៊ន មាឌធំជំបង សាក់ពេញទាំងដងខ្លួន ។ ទៅណា មកណា គាត់ឧស្សាហ៍សៀតកាំបិតស្នៀតមួយយ៉ាងធំនៅនឹងចង្កេះ ធ្វើឲ្យអ្នកផងញញើតគាត់ណាស់ ។

ថ្ងៃមួយ អុំទ៊ន បានហៅខ្ញុំមកជិត ។ គាត់ថាអាស៊ី ឯងចង់បេះនខ្វាក់ ឬទេ? ខ្ញុំឆ្លើយ ដោយមិនបាច់គិតថាចង់។

គាត់ក៏ចាប់យកមែកឈើ មកគូសក្រវេមក្រវាម ជាសញ្ញា តួអក្សរនខ្វាក់ គឺជាតួអក្សរន ដែលមានរាងសណ្ឋានកួចខ្វែង ជាត្រីកោណ (បិជ្រុង) ៙ នេះ សម្រាប់សរសេរចុះក្នុងផ្ទៃកន្សែងយ័ន្ត ក្នុងសម័យបុរាណ ដោយគេសន្មតថា ជាតួអក្សរពិសេស មានអនុភាពពូកែស័ក្តិសិទ្ធិ សម្រាប់ជួតក្បាល ចូលកាន់សង្គ្រាម...។ អ្នកដែលមិនចេះអក្សរ ច្រើននិយាយប្រាប់គ្នីគ្នាថា ៖ ខ្ញុំឥតចេះអក្សរមួយតួទេ សូម្បីតែនខ្វាក់ក៏ឥតចេះដែរ ។

អុំវ៉ែន បានប្រាប់ខ្ញុំ ថែមទៀតថា ជាវាសនា ដ៏ខ្ពង់ខ្ពស់របស់ក្មួយ ដែលបានចេះអក្សរ នខ្វាក់នេះ ។ សូមក្មួយខំប្រឹងរៀនគូស សរសេរឲ្យចេះចាំ សម្រាប់ទុកការពារខ្លួនទៅថ្ងៃមុខ ។

ខ្ញុំសែនត្រេកអរ ហើយឆ្លើយទៅអុំវិញថាបាទ ។ ក៏ប៉ុន្តែខ្ញុំនៅនឹកឆ្ងល់ ពិភាល់ក្នុងចិត្ត ត្បិតអ្នកភូមិទាំងអស់គ្នាតែងតែថា អុំវ៉ែនពុំចេះអក្សរមួយតួទេ ហេតុដូចម្តេចក៏គាត់ ចេះសរសេរអក្សរ នខ្វាក់នេះទៅវិញ? តែខ្ញុំពុំហ៊ានសួរដេញដោលគាត់ទេ ក្នុងរឿងនេះ ស៊ូទ្រាំតែលាក់ចម្ងល់ទុកក្នុងខ្លួនទៅ ។

ចាប់ពីថ្ងៃនោះមក ខ្ញុំត្រូវទទួលងារជាចៅនខ្វាក់ ៙ ឆ្លាក់ក្នុងចេះដូង សម្រាប់ប្រូង យោងវប្បធម៌ជាតិ ។

កាលខ្ញុំ ព្រមទាំងគ្រួសារបានភៀសខ្លួន មករស់នៅស្រុកបារាំង ចាប់ពីថ្ងៃ១១ កញ្ញា ១៩៨០ទៅ បាន ប្រហែល ៩ ឆ្នាំ ខ្ញុំ បានជួបនឹងប្អូន **ជួន គាម៉ិល** ដោយចៃដន្យនៅផ្ទះសម្លាញ់ម្នាក់ឈ្មោះ **ចែមចំរូន** ជាវិជ្ជបណ្ឌិត ដែលបាន ហៅខ្ញុំ ទៅទទួលទានបាយថ្ងៃត្រង់ ។ នៅពេលបាយក្នុងថ្ងៃនោះ មានគ្រួសារ **ចែមចំរូន**(ម្ចាស់ផ្ទះ) **សនសឿម កែមីណារេត ជួនគាម៉ិល ឃិមសាមុត**(ប្អូនប្រុសខ្ញុំបង្កើត) និងគ្រួសារខ្ញុំ ។

ក្រោយពីបានសំណេះសំណាលជាមួយ **ជួនគាម៉ិល** ខ្ញុំក៏ដក់ចិត្ត ក្នុងការបង្កើតអក្សរខ្មែរសំរាប់ប្រើប្រាសក្នុងកំព្យូទ័រ ។ កាលណោះ **គាម៉ិល** គេបានបង្កើតអក្សរខ្មែរជាដំបូង តាមភាសាប៉ាសស្កាល់ ដើម្បីឲ្យខ្ញុំយកទៅសាកល្បង ក្នុងការសរសេរអក្សរខ្មែរនៅក្នុងអរឌីណាទ័រ ។ អក្សរនោះពុំជាល្អទេ តែអាចអានបាន ។ ដល់ខ្ញុំបានចេះវាយអក្សរ បញ្ចូលក្នុង អរឌីណាទ័របន្តិចបន្តួច សម្លាញ់ខ្ញុំម្នាក់ជាបណ្ឌិតខាង

ច្បាប់អន្តរជាតិ ឈ្មោះ យឹមអ៊ី ដែលធ្លាប់បានរៀនសូត្រជាមួយគ្នា ក្នុងឆ្នាំ១៩៦១-៦២ នៅថ្នាក់ ទីបញ្ចប់ នៅវិទ្យាល័យព្រះស៊ីសុវត្ថិ បានយកអត្ថបទ សរសេរ ដោយ ព្រះភិក្ខុ យសម៉ុត ក្នុងបំណងដើងថា សាមគ្គីជាកម្លាំង ។ ខ្ញុំក៏សាលល្បង បម្លងអត្ថបទ នោះ ដាក់ ក្នុង អរឌីណាទ័រ រួចក៏បញ្ចេញ អត្ថបទអក្សរពុម្ព ប្រគល់ទៅយឹមអ៊ី ដើម្បីយកទៅប្រគេលោកគ្រូយសម៉ុតវិញ ។ ក៏ប៉ុន្តែ អក្សរខ្មែរ សរសេរ ដោយ អរឌីណាទ័រ នៅពេលនោះ ពុំសូវល្អទេ ខ្ញុំក៏ងាករេទៅរកពុម្ពអក្សរខ្មែរផ្សេង ។ ខ្ញុំក៏បានជួបនឹងប្អូន គួចសុខមារ៉ា ដែលជាវិស្វករធ្លាប់ បាន ធ្វើការជាមួយគ្នា ក្នុងក្រសួងអយស្ម័យយានកម្ពុជា នៅ ឆ្នាំ ១៩៧០ ។ គួចសុខមារ៉ា បានបម្លងពុម្ពអក្សរខ្មែរ បានមកពីកាណាដា ដែលអាចប្រើប្រាស បាន នៅក្នុងវិនដូ ៣.១ មកឲ្យខ្ញុំប្រើ ដោយក្តីពេញចិត្ត នឹងអក្សរនោះណាស់ ។

ដោយសារ ការព្យាយាមស្រាវជ្រាវរាវរក បង្កបង្កើត ពុម្ព អក្សរខ្មែរ គ្មាន ពេល ឈប់ឈរ ថ្ងៃមួយ តាម៉ិលក៏បង្កើត បានពុម្ពអក្សរខ្មែរ ដ៏ល្អបន្តិរ យកមកពិគ្រោះនឹងខ្ញុំថា គួរដាក់ឈ្មោះ ហៅថា ពុម្ពអក្សរនខ្វាក់ ៙ ។

ឥឡូវពុម្ពអក្សរនខ្វាក់៙បានប្រទាក់ក្រឡានៅលើបណ្តាញឥន្ទេរណេត ត្រដែក ក្នុងបណ្ណាល័យខ្មែរក្រោមការឧបត្ថម្ភនៃសមាគមខ្មែរសកល http://bible.aku.free.fr ។

**ផ្កាចម្រុះពណ៌**

នាងហុចទឹកដោះ

ខ្ញុំស្រណោះដៃ

៙៙៙

ឆ្នាំ១៩៥០ ដោយសារការទាមទារ ពីបងស្រីបង្កើតរបស់ខ្ញុំ ឈ្មោះអាន ខ្ញុំក៏ត្រូវបាន ឪពុកម្តាយបិញ្ចឹមខ្ញុំ បញ្ជូនឲ្យទៅ រៀនអក្សរខ្មែរ នៅឯក្រុងបាត់ដំបង ។

ថ្ងៃដំបូង យាយខ្ញុំ ឈ្មោះអ៊ាន គាត់ បាននាំខ្ញុំនិងប្អូន ប្រុសខ្ញុំឈ្មោះសាមុត ទៅចុះឈ្មោះរៀនអក្សរនៅសាលាវត្ត ម្មុទ្ធារាម ជាមួយព្រះភិក្ខុសង្ឃ ព្រះនាមតូរិន ។

លោកគ្រូគ្មិនទទួលចុះឈ្មោះខ្ញុំនិងប្អូនខ្ញុំ ក៏ប៉ុន្តែលោកបានប្រគល់ខ្ញុំនិងប្អូនខ្ញុំទៅឲ្យលោកគ្រូឆនបង្ហាត់ ព្រោះព្រះអង្គត្រូវជាប់បង្ហាត់សិស្សថ្នាក់ខ្ពស់ជាង ។

សាលារៀន នៅក្នុងសាលាធទាន គ្មានបិទបាំង ដោយជញ្ជាំងទេតីល្ហល្ហេវ សិស្សមើលឃើញគ្នាទៅវិញទៅមក ទោះសិស្សថ្នាក់ ក៏ដូចសិស្សទើបនិងចូលរៀន ។

សិស្សលោកគ្រូគ្មិនមានតុវែងនិងជើងម៉ាវែងអង្គុយ។
សិស្សលោកគ្រូឆនខ្លះមានតុវែងនិងជើងម៉ាវែងអង្គុយ ខ្លះទៀត អង្គុយលើកៅអីវែងដែលមានបង្អែក គ្មានតុសំរាប់សរសេរលើទេ ព្រោះកូនសិស្ស មានតែក្ដារឆ្នួនមួយនិងដីស តែប៉ុណ្ណោះ ។ ប្អូនខ្ញុំអង្គុយជិតខ្ញុំជាមួយអាខិន នៅលើកៅអីផ្អែកមួយវែង ។

ចំពោះសិស្សថ្មី លោកគ្រូដាក់ច្បាប់ឲ្យរៀនសរសេរ និងអានតែប្រាំតួទេ គឺ ក ខ គ ឃ ង លុះត្រាតែចេះអានរត់មាត់ និងចេះសរសេរស្អាត់ ។

ថ្ងៃទី១ខ្ញុំខំធ្វើតាមគ្រូ ដល់ថ្ងៃទី២ ខ្ញុំធុញទ្រាន់ ព្រោះខ្ញុំសរសេរតែមួយភ្លែតទៅ ក៏ធ្វើបានទាំងប្រាំតួ និងចេះអានទៀតផង ពីព្រោះខ្ញុំធ្លាប់បានរៀនអក្សរសៀមនៅវត្តបែង ហើយអក្សរខ្មែរ ក៏ស្រដៀងនឹងអក្សរសៀមដែរ មានសណ្ឋានខុសមន្តិចបន្តួច ខុសគ្នាខ្លាំងត្រង់អក្សរខ្មែរមានសក់ ឯអក្សរសៀម គឺត្រងោលតែម្ដង ។

ខ្ញុំក៏ចាប់រៀនសរសេរ អក្សរផ្សេងទៀត ដែលមានគំរូ នៅលើក្ដារខៀនខ្មៅ បញ្ឈរនៅពីមុខ ។ នៅពេលដែលខ្ញុំសរសេរបានពីរបីតួអាខិនក៏ប្រាប់ខ្ញុំថាប្រយ័ត្នលោកគ្រូវាយ ឯងសរសេរយ៉ាងហ្នឹង ។

ឮតែពាក្យថាលោកគ្រូវាយខ្ញុំភ័យ ក៏និនាយតតិបតតុប ទៅរក អាងិន ថា អញសរសេរលេងទេ រួចក៏ចាប់លប់អក្សរ ដែលបានសរសេរនោះអស់ទៅ ខ្លាចក្រែងអាងិន ទៅពិតលោកគ្រូ ។ ម្យ៉ាងទៀត អាខិននេះ វាមានមាឌធំជំបង ហើយវាចូលរៀនមុនខ្ញុំ ជាងមួយខែ ហើយ នៅតែអន្ទែលអក្សរប្រាំអង្គនោះ វាពិតជាស្គាល់លោកគ្រូជាងខ្ញុំ ខ្ញុំពុំហ៊ានរឹងទទឹងនឹងវាទេ ។

ថ្ងៃទី៣ខ្ញុំរឹតតែនៅមិនសុខ ចេះតែចង់រៀនសរសេរ អក្សរ បន្ត បន្ទាប់ម្ដងនេះ នៅពេលសរសេរខ្ញុំ បែរមុខទៅរកអាងិន ដើម្បីកុំឲ្យវាឃើញ ក្ដារឆ្នួនខ្ញុំថាមានអក្សរអី ។ ខ្ញុំលួចសរសេរជារៀងរាល់ថ្ងៃ លុះត្រាតែមិនបានបីអាទិត្យផង

ខ្ញុំក៏បេះ ព្យញ្ជនៈ ទាំង៣៣តួ ហើយ និងស្រៈទាំងអស់ ។ ទទួល ដល់ពេល លោកគ្រូ ហៅសិស្ស ទៅ បណ្តាំអក្សរ ល្មម គឺសួរ ដេញដោយនូវ បំណោះ ដឹង ។ ខ្ញុំក៏មាន ឈ្មោះ ត្រូវ ទៅ ឲ្យលោកគ្រូ ដាក់អក្សរ បណ្តាំដែរ ។ លោកគ្រូ ចោទសួរ សិស្ស ម្តងមួយៗ ។ ធ្លាក់ដល់វេន ខ្ញុំ លោក ចាប់ សួរ ពីព្យញ្ជនៈ ខ្ញុំឆ្លើយត្រូវ ទាំងអស់ ។ ដល់មកស្រៈ ខ្ញុំ នៅមានចន្លោះត្រង់ស្រៈ ើ និងស្រៈ ៀ ព្រោះមានស្រៈ េ ផង និងសញ្ញា ផ្សេងទៀត ផង ខ្ញុំក៏ទ្រឹង មួយសន្ទុះ ទើបខ្ញុំឮសំឡេង ខ្សឹប របស់អារ៉ាន់ ដែល ឈរ ពីក្រោយខ្នង ប្រាប់ខ្ញុំថា សំឡេងស្រៈនោះ ខ្ញុំក៏ថាតាម រួច លោកគ្រូយល់ព្រមថាត្រូវ ទើបលោកគ្រូ ឲ្យខ្ញុំទៅ រៀន ប្រកប ផ្ញើ ជើងនិងបំបែក ជាកូនសិស្ស ដែលបាន ចូលរៀន មុនខ្ញុំ ជាង ពីរខែ មកហើយ ។ ខ្ញុំ បាន ឡើងថ្នាក់ ចោល អាចិន ដែល ហាក់ដូចជា អន់ចិត្តនឹងខ្ញុំផង បានជា ពុំសូវនិយាយស្តី នឹងខ្ញុំ ។

ចាប់តាំងពីបាន ចូលរៀន ថ្នាក់ បំបែក ខ្ញុំបាន ជួប នឹង សិស្ស ប្រុស ប្រាំ នាក់ គឺ អារ៉ាន់ អាស្រ៊ុន អាសខ អាថខ និង អាគរឹម សិស្សស្រី ៣នាក់ គឺនាង សារេត នាងម្ចាឌីម៉ា និង នាងស៊ីវហេខ ។

អារ៉ាន់ជាកូនអ្នកភ្ជុំសំពៅ ។ វាជាក្មេងវត្ត នៅកុដិលោកគ្រូឝ្វិន ។

អាសខ ជាកូនអ្នករហាត់ទឹក ។ វាជាក្មេងវត្ត នៅកុដិ ជាមួយ អារ៉ាន់និងអាចិន ។

អាស្រ៊ុន ជាក្មេងវត្ត នៅកុដិខាងជើងព្រះវិហារ វានៅ បម្រើ លោកគ្រូ សង្ក្រាជ រាជធម្មឌិត ដែល អាពាធ គង់នៅតែក្នុងព្រះវិហារ ។ រាជធម្មឌិត ត្រូវជាសាច់ ញាតិ ខាង ឪពុកខ្ញុំដែរ ។ ជួនកាល អាស្រ៊ុន នាំខ្ញុំទៅថ្វាយ បង្គំសម្តេចព្រះគ្រូម្តងៗ ព្រះអង្គតែង មាន ពុទ្ធដីកា សួរខ្ញុំថា ឯងឈ្មោះអី ជាកូនចៅអ្នកណា? លុះខ្ញុំពិតពុទ្ធដីការព្រះអង្គថា ខ្ញុំ ឈ្មោះស្វគ ឪពុក ម្តាយខ្ញុំ ឈ្មោះម៉ៃ-អ៊ាម ព្រះអង្គក៏ទ្រង់មានពុទ្ធដីកា បញ្ជាក់ថា ៖

- អើ! ឯងជាកូន អាម៉ៃនិងនាងអ៊ាម ទេតើ?

អាគរឹមជាប្អូន នាងម្ចាឌីម៉ា ។ ទាំងពីរនាក់ បងប្អូន ជាកូន កាត់ ឪពុក អារ៉ាប់ ម្តាយ ខ្មែរ ដែលសង់រោង នៅ ខាងជើងវត្ត និងរកស៊ីបិញ្ចឹម ពពែនិងចៀម ។

នាងសារេត ជាក្មេង កំព្រា រស់នៅ ជាមួយ ឪពុក មា ម្តាយ មីង នៅជាប់របងវត្ត ជ្រុងខាងត្បូងវត្ត ។

នាងស៊ីវហេង មានប្អូន ប្រុសម្នាក់ មករៀន ជាមួយដែរ ឈ្មោះ វា អាចេងជន ផ្ទះ នៅ ខាងត្បូងវត្តសង្កែ ។

វត្តសង្កែ ជវង្កែតាមធម៌មហានិកាយ ស្ថិតនៅ ជាប់ របង ពីខាងលិចធៀង ទៅត្បូង បន្តិចពីវត្តបុប្ផារ៉ាមដែលវិលតាមធម៌ធម្មយុត្តិ ។

ចំណែកខ្ញុំ នៅចំពីត្បូងជាប់របងវត្តបុប្ផារ៉ាម និងចំពីកើតវត្តសង្កែ ។

យើងទាំងអស់គ្នា កូនសិស្សប្រុស-ស្រី កំពុងតែរៀន ប្រកប ក កា កិ កី ក៏ស្រាប់តែលាន់ ឮពាក្យ ពីក្នុងព្រៃ ខាង លិច វត្ត មកថា ៖ ក កា កិ កី មិនទាន់ដឹងអី ឃើញ ក គេ ល្អូន ។ ឃ្លាទាំង នេះ ហាក់បីដូចជាអុចអាល ឲ្យកូនសិស្ស ប្រុស-ស្រីក្នុងវ័យ ស្ទើរ ជំទង់ លិចលង់ក្នុងសេចក្តីស្នេហា ព្រោះ ថា ទោះ បី នៅក្មេងយ៉ាងណា កូនខ្មែរពូកែ ខាង យល់ និង ចេះ ប្រើ ពាក្យ ត្រលាស់ យ៉ាងស្ទាត់ជំនាញណាស់ ។

មែនពិត ខ្ញុំ កំពុង តែសរសេរ ក កា កិ កី ក៏ក្រឡេក ទៅ ឃើញ វង្វង់ មុខ នាងសារេតដ៏កំប្លង់ៗ នាងពិតជា នារី ខ្មែរ ដ៏មាន សម្រស់ ។ តែនាងហ្វាទីម៉ា ក៏ស្រស់មិនចាញ់នាងសារេត ដែរ ។ នាង ជាកូន អារ៉ាប់ កាត់ ខ្មែរ តែពុំសូវចេះនិយាយ ស្តី ប៉ប៉ាច់ ប៉ប៉ោច ចេះតែញឹមៗ ។ ចំណែក ឯនាងស៊ីវហេង ជាកូនចិន រស់នៅតែជាមួយ ម្តាយ និង ជាមួយនឹងប្អូនប្រុសម្នាក់ ។ សាច់ នាង ស ថ្លា ប្រៀប ឧបមា បី ដូច ជា សំពត់ ទេស ឯក ហែក នៅ ក្នុង កណ្តាលកី កម្រនឹងរកស្រីណាឲ្យល្អដូច ម៉្លោះ ហើយវា ធ្វើឲ្យ ខូចចិត្តដល់ កូនសិស្ស ទាំងអស់ មិនថាសិស្ស គេ ឬ សិស្សខ្ញុំ ។

រៀនបានតែបីខែ កូនសិស្ស លោកគ្រូផន ក៏ត្រូវ បែកគ្នា ដោយ សារខ្ញុំនិងសារេត ត្រូវ ប្រឡងជាប់ ទៅ រៀន នៅ ថ្នាក់ បរិវេច្ឆណដ្ឋាន ឯទក្ខណសាលា បឋមសិក្សា ទល់មុខ វត្តកំផែង ចម្ងាយប្រមាណ ពីរគីឡូម៉ែត្រ ពីផ្ទះ ។

មុននឹងបែកគ្នា ខ្ញុំនិងអាស្រ៊ុនបានត្រូវ អាគរីម សុំ អញ្ជើញ ឲ្យ ទៅ លេងផ្ទះ ។ ឪពុកម្តាយ អាគរីម និងនាងហ្វាទីម៉ា បាន ទទួល ខ្ញុំ និង អាស្រ៊ុន ដោយ រាក់ទាក់ ជាទីបំផុត ។ ម្តាយ អាគរីម បាន មាត់ បាន ក ណាស់ តែឪពុក វា ហាក់ដូច ជាហ្នឹងហ្នាត់ ប្រហែល ជា គាត់ ពុំ សូវ ចេះ ភាសាខ្មែរ ទេ ក៏ មិនដឹង ។ តែខ្ញុំ ចេះលួចសំឡឹង មើលមុខគាត់ ហើយ ចេះតែ ញញើត គាត់ ណាស់ ។

ការទទួលភ្ញៀវនៅពេលនោះគ្មានអ្វីក្រៅពីទឹកដោះពពែ ដែលនាងហ្វាទីម៉ា ត្រូវម្ដាយប្រើឲ្យទៅរឹតយកមកថ្មីៗ ។ យើងទាំងអស់គ្នា លើកបំពង់ទឹកដោះពពែផឹកក្អឹកៗ យ៉ាងក្អាកក្អាយ ដោយផ្ទុះសំណើច នឹងខ្ញុំដែលហាក់ដូចជាប្រឹមប្រុមព្រោះពុំសូវប៉ិន ។

ការបញ្ចឹមជីវិត ដោយទឹកដោះពពែ បានធ្វើឲ្យនាងហ្វាទីម៉ា មានព្រលឹងដ៏ទ្រលុកទ្រលន់ ពន់ប្រមាណ ដ៏មានអប់ក្លិនទឹកសុដនពពែដ៏ឈ្ងុយឈ្ងប់ ។

**ផ្កាចកចាកបឹង**

ផ្កាចកចាកបឹង រំពឹងសមុទ្រ
នាំធាតុមិនសុទ្ធ បរិសុទ្ធទៅផង ។
ផ្កាចកខ្មែរក្រោម ប្រលោមស្នេហ៍ស្នង
បោះដៃត្រកង អន្ទងចិត្តខ្ញុំ ៕៚

ឆ្នាំ១៩៩០-៩១ ខ្ញុំជាសិស្សសំណព្វអ្នកគ្រូថោងលិន ។ អ្នកគ្រូថោងលិននៅក្រមុំព្រហ្មចារី ប្រកបដោយរូបឆោមលោមពណ៌សម្បុរសជ្រះជាកញ្ញាល្អឯក គាប់ភ្នែកអស់ទាំងគ្រូ ទោះនៅកម្លោះក្ដីឬក៏មានប្រពន្ធក្ដី តែងតែស្រមៃលើអ្នកគ្រូខ្ញុំ ស្ទើរតែគ្រប់គ្នា ។

អ្នកគ្រូមានកង់ម៉ាកពើហ្សូស្រីជិះទៅបង្រៀនយ៉ាងសង្ហារ តើមិនឲ្យបុរសណាមិនស្នេហាលើអ្នកគ្រូទៅរួច?

ក្រោយម៉ោងរៀន អ្នកគ្រូតែងប្រើខ្ញុំឲ្យជូតកង់របស់អ្នកគ្រូឲ្យយ៉ាងភ្លឺរលោង ។

អ្នកគ្រូពេញចិត្ត នឹងខ្ញុំណាស់ ព្រោះខ្ញុំជាសិស្សបំរើគាត់ដោយយកចិត្តទុកដាក់ និងជាសិស្សឧស្សាហ៍ ហើយរៀនពូកែទៀតផង ។ អ្នកគ្រូតែងប្រើខ្ញុំឲ្យកាន់បញ្ជីហៅ

ឈ្មោះ និង កំណត់ពិន្ទុសិស្ស ទៅទុក នៅផ្ទះគាត់ជារៀងរាល់ថ្ងៃ ព្រោះផ្ទះខ្ញុំនៅជិតផ្ទះគាត់ ។

អ្នកគ្រូ មានឪពុកឈ្មោះកែម របររកស៊ីធ្វើប៉ូង់តុង នៅសាលាខេត្ត មានម្តាយឈ្មោះអ៊ួន ។

កែម-អ៊ួន ស្វាមីភរិយា មួយគូនេះ មានដើមកំណើតជាខ្មែរក្រោម ។ គាត់មានកូនស្រីបីនាក់ គឺ អ្នកគ្រូថោងលិន នាងណារេត និងនាងណារិន។

កាលណាខ្ញុំរលឹកដល់ពាក្យថា ខ្មែរក្រោម ខ្ញុំតែងនិយម ហៅខ្មែរក្រោមថា ស្រី ព្រោះអ្វី៖

ទី១ ពូកែមមីងអ៊ួន ដែលមានមានកូនសុទ្ធតែស្រី ។

ទី២ គាត់ភិតភ័យភៀសខ្លួន ខ្លាចយួន ដែលតាំងខ្លួនជាម្ចាស់ទឹកដីកម្ពុជាក្រោម តាំងពីឆ្នាំ១៩៤៩មកម្ល៉េះ ដេញបាញ់ តាមកាប់សម្លាប់ ឲ្យផុតពូជពង្ស ដោយល្ងង់លែងក្លាហាន ហ៊ានប្រឆាំង តតាំងតបវិញ ខ្លាចគេបណ្តេញរបៀបមនុស្សកំសាកញី ។

ទី៣ ខ្ញុំញញើតនឹង យកន័យមកសំដែង ដោយខ្លាចវាស្លែង ក្រែងនាំឲ្យទំនាស់ដល់អធ្យាស្រ័យនៃលោកអ្នកអាន ដែលគាត់ស្មានយល់ត្រូវ ជាពាក្យអាស្រូវ ផ្តេសផ្តាស ព្រោះអីស្ត្រី រមែងស្ថិតនៅ ក្រោមអាជ្ញាធរនៃបុរស ។

នាងណារេត អាយុជំណាលខ្ញុំ នាងមានសម្បុរខ្មៅស្រអែម តែនាងល្អស្រស់សម្តីក៏ពិរោះពុំបាញ់អ្នកគ្រូទេ ។ ពេលជួបនាងម្តងៗ ខ្ញុំមិនដឹងជានិយាយ ស្តីអ្វីកើត ព្រោះបេះដូងរបស់ខ្ញុំវាលោតខុសចង្វាក់ ។ នាងតែងមកទទួល យកបញ្ជីពីខ្ញុំ ស្ទើងតែរាល់ដង ធ្វើឲ្យខ្ញុំមានបំណងទៅលើនាងរឹតតែច្រើនដែរ ។

ថ្ងៃមួយ នៅរដូវបូលឆ្នាំខ្មែរ អ្នកភូមិវត្តសង្កែនិងវត្តបុប្ផារ៉ាម បានស្រាក់លុយគ្នា ជួលឡានទ្រុង ទៅលេងក្រុងអង្គរ ។ ខ្ញុំបានជូនម្តាយបិញ្ចឹមខ្ញុំ ទៅជិះឡាន ពេលនោះ នាងណារេត ក៏ជូនម្តាយទៅដែរ ។ ដល់ឮថា នាងណារេតបានទៅលេងក្រុងអង្គរដែរ ខ្ញុំក៏ទាមទារម្តាយខ្ញុំ សុំទៅជាមួយផង។ ម្តាយខ្ញុំ ហាក់ដូចជាមិនព្រម តែដល់ខ្ញុំយំ ហើយរត់ឡើងឡាន គាត់ក៏មិនថាអី ដោយក្តីអាណិតខ្ញុំ ទាំងគាត់ ទាំងអ្នកជិះក្នុងឡាន ទាំងតៃកុងឡាន ។

ខ្ញុំសែនពេញចិត្តណាស់ហាយ ។

ទៅដល់សៀមរាប ឡានក៏បត់ឆៀងចូលទៅបតនៅមុខព្រះលានជ័យ ដែលនៅលើទីនោះគេមានរៀបចំពិធីយ៉ាងឱឡារិក ដើម្បីទទួលលោកជាបឈ្នះ ។

រំពេចនោះ ស្រាប់តែគេផ្លុំកញ្ចែភ្លេចធ្លាប ឲ្យសញ្ញាថា លោកមេទ័ព នឹងអញ្ជើញមកដល់ឥឡូវហើយ ហើយគេស្រែកបញ្ជាឲ្យអ្នកទាំងអស់គ្នា អង្គុយចុះ ហើយកុំឲ្យងើបមុខមើលឲ្យសោះ កាលណាលោកមេទ័ពមកដល់ ។ ចាស់ៗធ្វើតាមបញ្ជាគ្រប់គ្នា មានតែនាងណារេត និងខ្ញុំទេ ដែលក្រាបដែរ តែលួចសម្លឹងរកមើលថាតើអ្នកណាទៅ ដែលជាមេទ័ពនោះ?

ខ្ញុំរវៀសរវៃក្អែកណាស់ ឲ្យតែនាងណារេតមើលអី ខ្ញុំក៏ឃើញនោះដែរ ព្រោះខ្ញុំនៅតែក្បែរៗនាង ហើយម្ដាយនាងក៏នៅក្បែរម្ដាយខ្ញុំដែរ។

កុមារាកុមារីទាំងពីរ ហាក់ដូចជាយល់ស្គាល់ចិត្តគ្នាណាស់ ។

យើងបានដើរទស្សនាប្រាសាទនានា ដោយពេញចិត្តត្បិតបុរាណវត្ថុជាស្នាដៃនៃបុព្វបុរសខ្មែរដ៏ល្អឯក ។

ក្រោយពីទស្សនាភ្នំបាខែង ឡានបើកសំដៅ ឆ្ពោះទៅកាន់ទន្លេសាប ។ ឡានបានឈប់នៅជើងភ្នំក្រោម ដើម្បីនឹងឲ្យអ្នកដំណើរបានឡើងទៅខាងលើ មើលព្រះវិហារ និងអណ្ដូងព្រេង ដែលគេតែងដងទឹកមិនចេះរីង មិនចេះអស់សោះ គឺកាលណាគេបានដងមួយផ្ដិល នៅសល់ទឹកក្នុងអណ្ដូងមួយផ្ដិល ។ គួរឲ្យអស្ចារ្យណាស់ ចំពោះទឹកអណ្ដូងព្រេងនេះ!

ម្ដាយណារេត និងម្ដាយខ្ញុំបានឡើងទៅមុន ទុកឲ្យណារេតនិងខ្ញុំរត់ឡើងតាមក្រោយ ដោយកាន់ដៃគ្នា គ្មានដឹងថាហត់នឿយអ្វីបន្តិចបន្តួចទាល់តែសោះ ។ បើសិនយើងជាក្រមុំ និងកម្លោះ ប្រហែលជាចាស់ៗគាត់ប្រកាន់ហើយ ។ ដល់ទៅមាត់អណ្ដូងព្រេង ដែលម្ដាយណារេតកំពុងតែអោនដងទឹក យកមកស្រឡាបមុខ សុំសិរីសួស្ដី គាត់ងាកមកស្ដីឲ្យនាងណារេតថា ឯងចូលចិត្តតែដើរជាមួយក្មួយសួគ៌ ។ នាងហាក់ដូចជាអៀនហើយអន់ចង់ ដល់ក្រោយមកនាងមកជិតខ្ញុំ ដោយលាក់លៀម រីឯខ្ញុំក៏ហាក់ដូចជានឹកអៀន និងអន់ចង់ផងដែរ ។

បុណ្យចូលឆ្នាំខ្មែរ បានកន្លងទៅ យើងទាំងពីរ ក៏អស់ផ្លូវសប្បាយរីករាយតទៅទៀត !

នាងរៀននៅថ្នាក់លើខ្ញុំមួយថ្នាក់ ៗ នេះ ក៏ជាគ្រោះថ្នាក់ដល់ខ្ញុំដែរ ព្រោះធម្មតា គ្មាននារីណាទៅស្រវារកគូស្រករ ដែលរៀននៅថ្នាក់ទាបជាងខ្លួនទេ ! តែសេចក្តីលួចស្នេហ៍នៅតែដកពុំរួច!

នេះជាព្រេងវាសនា ឬ ក៏ជាស្រមោលគូកម្ម ដែលមកបញ្ឆោតដួងអារម្មណ៍ខ្ញុំឲ្យវង្វេង ៗ

**មុត្រនោល**

**ពាំនោលពុំចេញ**

៙

សិក្សាអប់រំ សន្សំប្រាជ្ញា ជាមួយអ្នកគ្រូថោងលិន ខ្ញុំបានទទួលលទ្ធផល ជាសិស្សលេខ២ បន្ទាប់ពីសម្លាញ់ខ្ញុំម្នាក់ ឈ្មោះ ជៀមវៀម ដែលជាសិស្សលេខ១ ៗ

ឆ្នាំ១៩៨១-៨២ ខ្ញុំត្រូវបានឡើងថ្នាក់អាទិកដ្ឋាន ក្រោមឱវាទរបស់លោកគ្រូធំសុន ៗ

ឆ្នាំនោះ មានភ្លើងឆេះសាលារៀនមួយខ្នង អស់បន្ទប់រៀនពីរបី លោកគ្រូធំសុនត្រូវនាំសិស្សទៅសុំលោកគ្រូចៅអធិការវត្តកំផែង ដើម្បីបង្រៀនក្មេង ៗ

កាលណោះ ខ្ញុំត្រូវជាកូនសិស្សសំណព្វ ព្រោះខ្ញុំពូកែបំណោទជាងគេ និងពូកែខាងតែងសេចក្តីថែមទៀត ៗ

តែលទ្ធផលនៅចុងឆ្នាំ ខ្ញុំជាសិស្សលេខ៣ អាវៀមលេខ២ ព្រោះមានអាតោស៊ុនអេង មកពីឧត្តរសាលាបឋមសិក្សា បានលេខ១ ៗ

ឆ្នាំ១៩៨២-៨៣ ខ្ញុំត្រូវបានឡើងថ្នាក់មជ្ឈិមដ្ឋាន ថ្នាក់ទី១ ក្រោមឱវាទរបស់លោកគ្រូស៊ុនលី ៗ

កាលណោះ ខ្ញុំត្រូវជាកូនសិស្សសំណព្វរបស់លោកគ្រូស៊ុនលី ព្រោះខ្ញុំពូកែបំណោទជាងគេ និងពូកែខាងតែងសេចក្តីថែមទៀត ៗ

ឆ្នាំនេះ អាឡេង ដែលជាសិស្សស្អាតសង្ហារ ត្រូវទទួល ព្រេងវាសនា កម្មពៀរ ជាមួយ នាងអ៊ន ដែល រៀន នៅថ្នាក់ បរិវេចូនដ្ឋាន ។ ចំពោះខ្ញុំ នាងអ៊ន មិនជាល្អណាស់ណាទេ បាញ់នាងណារអេតរបស់ខ្ញុំឆ្ងាយដូច មេឃ ហើយនិងដី តែចំពោះអារៀម នាងជាទេពធិតា តែម្តង។ ពាក្យបាស់លោកពោលថា “ឃ្លានឆ្ងាញ់ ស្រឡាញ់ល្អ” ពិតជាមិនខុសមែន ។

នៅពេលចេញលេងម្តងៗ អារៀម តែងបបួលខ្ញុំ ដើរ ទៅជិត ថ្នាក់នាងអ៊ិន ។ ខ្ញុំ ឃើញ ជាញឹកញាប់ នាងអ៊ិន ហុចប្រាក់ មកឲ្យអាឡេង ជាញយដង ។ កាល បើបានលុយ អាឡេង តែងប៉ាវខ្ញុំ នូវនុំបំណី ។ ខ្ញុំក៏បានស្គាល់រសជាតិ ផ្អែមមាត់ដោយសារ រឿងស្នេហា របស់អាសម្លាញ់នេះ ។

លទ្ធផល បុងឆ្នាំ អាស៊ុនអេង បានលេខ១ ខ្ញុំបាន លេខ២ អាឡេង លេខមធ្យម ។ រឿងនេះ គឺ បណ្តាលមកពីសេចក្តីស្នេហា នៅក្នុងវ័យសិក្សា ។ តាមធម្មតា ទោះខ្ញុំខំ រៀន យ៉ាង ណាមិន ឈ្នះ អាឡេងឡើយ ព្រោះវា មាន បងប្រុស ម្នាក់ឈ្មោះឡេងរួមដែល រៀន នៅថ្នាក់ខ្ពស់ជាង វា ៤ ថ្នាក់ គឺនៅថ្នាក់ទី ៦ នៃ អនុវិទ្យាល័យ ព្រះមុនីវង្ស ។ កាលណាវា ទាល់ជំរេះ វាតែងតែ ទៅពឹងបងវា ឲ្យជួយ វែកញែក បំបែក បំភ្លឺផ្លូវ ។ បំណែកខ្ញុំ គ្មានអ្នកណាជួយទេ រំពឹងលើបងស្រី គាត់ចេះ ភាសាសៀម បន្តិច បន្តួច ស្តួប ស្តើងពេក នឹងរំពឹង លើលោកឪពុក អ្នកម្តាយ ក៏ពុំបានទៅទៀត នៅសល់តែខ្លួន ជាទីពឹងរបស់ខ្លួន។ សមដូចព្រះពុទ្ធដីកាទូន្មានថា៖ “អត្តាហិ អត្តនោនាថោ” ។

ឆ្នាំ១៩៨៣-៨៤ លោកគ្រូស៊ុនឈី បានផ្លាស់ទៅបង្រៀន សិស្ស នៅថ្នាក់ បឋមដ្ឋាន ថ្នាក់ទី២។ ខ្ញុំនៅតែជាសិស្សសំណព្វ របស់លោកគ្រូ ស៊ុនឈី ដដែល។

ដល់ពេលឡើង ទៅថ្នាក់ឧត្តមដ្ឋាន ខ្ញុំជាសិស្ស លេខ១ បន្ទាប់មក ម៉ៅ អួច បាន លេខ២ ។

នៅក្នុងឆ្នាំនេះ មាន ការប្រឡងយក អាហារូបករណ៍ ផង ។ ខ្ញុំ និងអាអួច ត្រូវ លោកគ្រូ ជួយ ធ្វើពាក្យដាក់សុំប្រឡងដែរ ។

ការប្រឡងធ្វើនៅ មជ្ឈឹមសាលា បឋមសិក្សា ។ គ្រូ ដែលត្រួតមើលសិស្ស នៅក្នុងបន្ទប់ប្រឡង របស់ខ្ញុំ គឺលោក គ្រូធំសុន ទាំងសាច់ទាំងឈាម ដែលបានផ្លាស់ មក មជ្ឈឹមសាលាបឋមសិក្សា ជាងពីរឆ្នាំហើយ ចាប់តាំងពីគាត់ឈប់បង្រៀនខ្ញុំមក។

សិស្សចាស់ គ្រូចាស់ ប្រទះជួប ដោយឥតគ្រោងទុក ៗ ទ្រូងខ្ញុំ បុក ក្តុកៗ ដោយភ័យ ផងអរផង ៗ ភ័យក្រែងលោកគ្រូចាស់ ភ្លេច សិស្សសំណព្វទៅហើយ ៗ អរ ព្រោះនឹង បាន គ្រូចាស់ជួយ សម្រួល បាន ខ្លះ ក្នុងការប្រឡង ៗ

វិញ្ញាសារ សំរាប់ប្រឡង មាន បីមុខ គឺ បំណោទ១ សរសេរ តាមសូត្រ ជាភាសាបារាំង១ និងគូរគំនូរ១ ៗ

ខ្ញុំ ភ័យតែលើ សរសេរតាមសូត្រទេ ៗ ចំពោះវិញ្ញាសាពីរ មុខទៀត ជាជំនាញការរបស់ខ្ញុំហើយ គឺ ខ្ញុំ ពុំដែលធ្លោយ ម្តងណាទេ ៗ ចំពោះ បំណោទក្នុងក្បួន នព្វន្តទាំងបួនលេខ បើខ្ញុំនិយាយ ដោយពិត ហាក់ដូចជា ខ្ញុំអួត ព្រោះខ្ញុំ ពុំដែលបានពិន្ទុក្រោមពី ១០/១០ ទោះបីបំណោទនោះ មានការលំបាកយ៉ាងណាក៏ដោយ ៗ

រឿងគំនូរ ក្រៅពីគូរមុខមនុស្សបេញ ខ្ញុំតែងតែបានពិន្ទុល្អ ជានិច្ច ៗ

ចំពោះ សរសេរតាមសូត្រ ខ្ញុំមាន ការខ្សោយ បន្តិច បន្តួច តែកំហុស មិនហួសពី ១ភាគ១០ទេ ៗ

ថ្ងៃដំបូង ប្រឡងធ្វើបំណោទ ៗ ខ្ញុំច្បាស់ជាធ្វើបានត្រូវ ទាំងពីរ ៗ

ថ្ងៃ ពីរ ប្រឡង សរសេរ តាម សូត្រ ជា ភាសា បារាំង ៗ ខ្ញុំ ពុំជា ពូកែខ្លាំង តែខ្ញុំមិនជាខ្សោយណាស់ណាទេ ៗ ខ្ញុំ កំពុងតែរារែកនឹងពាក្យមួយ ដែលពុំដឹង ជាសំរេចសរសេរ យ៉ាងណា ព្រោះខ្ញុំ ពុំច្បាស់លាស់ ដោយខ្លួនឯង ៗ

ទន្ទួលលោកគ្រូធំស៊ុន ដើរមកពីក្រោយខ្នងខ្ញុំ ទំនងដូចជាចង់ មក មើល ថា តើខ្ញុំ សរសេរពាក្យទាំងឡាយបានត្រឹមត្រូវ ឬទេ ជាពិសេស ពាក្យដែលខ្ញុំ កំពុងតែអល់ឯកនោះឯង ៗ ខ្ញុំ ដឹងចិត្តលោកគ្រូ ខ្ញុំណាស់ តែគាត់ មកក្រោយខ្នងខ្ញុំ ហើយ ពិតជាមាន រឿងអ្វីប្លែកហើយ ៗ

កាលពីរៀន នៅសាលាវត្តកំផែង នៅពេលមួយ ក្នុងការសរសេរតាមសូត្រ ជាភាសា បារាំងនេះដែរ លោកគ្រូ ចង់វាយសិស្ស ពូកែៗ ណាស់ ព្រោះសិស្សទាំងនោះ ពុំដែលត្រូវរំពាត់ទេ ក្នុងការ សរសេរ តាម សូត្រជា ភាសា បារាំង ព្រោះលោកគ្រូបាន ដាក់កំណត់ថាសិស្សណា ខុសចាប់៥ទៅ ទើបត្រូវលោកគ្រូវាយ ហើយសិស្ស ដែលពូកែៗ ពុំដែលខុសលើសពី៥ដែរ ៗ

ខ្ញុំយល់ច្បាស់ពីបំណងរបស់លោកគ្រូខ្ញុំហើយ ខ្ញុំក៏ដាច់ចិត្តយកស្វាបប៉ាកាចុចលើពាក្យ ដែលខ្ញុំឆ្ងល់ ។ គាត់ក៏ដើរចេញ ដោយផ្ញើវាហិ ។ ខ្ញុំឆាប់យល់ន័យ ក៏កែពាក្យភ្លេត ។

ថ្ងៃទី៣ ប្រឡងគំនូរ គូរកែវដាក់ទឹក ។

លទ្ធផលប្រឡង ខ្ញុំបានជាប់លេខ១ ដោយបានពិន្ទុ ២៧/៣០ គឺ បំណោទ១០/១០ សរសេរតាមសូត្រ១០/១០ គំនូរ ៧/១០ ។ អាអួប បាន ២២/៣០ គឺ បំណោទ ៨/១០ សរសេរតាមសូត្រ ៩/១០ គំនូរ ៥/១០ ។

ពេលចូលកងធំ ខ្ញុំសង្ឃឹមថា នឹងបានចូលទៅរៀន ដោយមានអាហារូបករណ៍ គឺ ទទួលទានបាយនិងដេកនៅសាលា នៅមជ្ឈឹមសាលា បឋមសិក្សា ។

តែសេចក្តីសង្ឃឹម ក៏ក្លាយទៅជារលាយសូន្យ ។ ព្រោះខ្ញុំមិនត្រូវ បានទទួលទានបាយបួកទេ ដោយហេតុថា លោកមេឃុំ បានបញ្ជាក់ ក្នុងសំណុំលិខិត ដែលភ្ជាប់នឹងពាក្យ ដាក់សុំប្រឡង ថាខ្ញុំជាបុត្រទោល ចំណែកបាយបួកគេ ឲ្យតែសិស្សណា ដែលមានបងប្អូនច្រើន ។ តាមពិតខ្ញុំមាន បងប្អូនច្រើនដែរ តែម្តាយឪពុកខ្ញុំ បានឲ្យខ្ញុំទៅអុំខ្ញុំ ជួយចិញ្ចឹម បីបាច់ថែរក្សា ។

លេសយកមកសំអាងខាងលើនេះ ហាក់ដូចជាមិនសមទេ ជាអយុត្តិធម៌ចំពោះខ្ញុំ បើថាមិនឲ្យអាហារូបករណ៍ ក៏កុំអនុញ្ញាតិឲ្យខ្ញុំ ចូលប្រឡងពីដំបូងទៅ!

ឋិតនៅក្នុង សភាពអយុត្តិធម៌យ៉ាងនេះ ខ្ញុំក៏អស់ទឹកចិត្តរលីង ក្នុងការបន្តការសិក្សា។ ខ្ញុំទៅរៀន ដើម្បីគ្រាន់តែ វៀរបាកនូវសេចក្តីល្ងង់ខ្លៅ តែប៉ុណ្ណោះ ។ រៀនយូរៗទៅវាអត់ន័យ! ខ្ញុំលែងចង់ប្រកួតប្រជែងជាមួយសិស្សឯទៀតហើយ! ខ្ញុំរៀនយ៉ាងណាឲ្យតែបានឡើងថ្នាក់តែប៉ុណ្ណោះ ។ ចំពោះការប្រព្រឹត្តិយ៉ាងនេះ ជាការងាយស្រួលសោះចំពោះខ្ញុំ ។

នៅចុងឆ្នាំ ១៩៥៥ ខ្ញុំបានប្រឡងជាប់ សញ្ញាប័ត្របឋមសិក្សា ហើយបានប្រឡងជាប់ចូលរៀននៅថ្នាក់ទី៦ នៅអនុវិទ្យាល័យ ព្រះមុនីវង្ស ជាស្តាតរ ។

ឆ្នាំ១៩៥៥-៥៦ ខ្ញុំជាសិស្សថ្នាក់ទី៦ ។ វិជ្ជាដែលសិស្សត្រូវរៀនសូត្រ មិនជាលំបាកដាងនៅថ្នាក់ឧត្តមដ្ឋានទេ ។ ខ្ញុំរៀនផង ដើរលេងផង បានទទួលពិន្ទុសំរាប់

ឡើងថ្នាក់យ៉ាងធូរល្ហុយ ៗ ចំណែកការបង់បានលេខ១ ឬលេខ គ្រាន់បើជាងគេ នោះ ត្រូវបានខ្ញុំបោះបង់ចោល តាំងពីខ្ញុំប្រឡងប្អូកបានលេខ១ ហើយបណ្ដាលឲ្យខ្ញុំ កើតទុក្ខព្រួយអស់មួយជីវិត ព្រោះត្បិតអំពើអយុត្តិធម៌ !..

—ចប់ភាគ២—